# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១ អនក្រ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈប្រតិភូអន្តរក្រសួង
## ដើម្បីពិភាក្សាការងារជាមួយភាគីថៃ ស្តីពីការបើកច្រកទ្វារព្រំដែនអូរស្មាច់

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**ប្រការ១:** បង្កើតគណៈប្រតិភូអន្តរក្រសួងមួយ ដើម្បីពិភាក្សាការងារជាមួយភាគីថៃ ស្តីពីការបើកច្រកទ្វារព្រំដែន អូរស្មាច់ (កម្ពុជា) - ចុងជាំ (ថៃ) ដែលមានសមាសភាព ដូចខាងក្រោមនេះ :

១-ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២-ឯកឧត្តម **វ៉ា គឹមហុង** ប្រធានគណៈកម្មាធិការចំរុះកិច្ចការព្រំដែន សមាជិក

៣-ឯកឧត្តម **សូរ ទិចឆំរ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ សមាជិក

៤-ឯកឧត្តមអភិបាលខេត្តឧត្តរមានជ័យ សមាជិក

៥-ឯកឧត្តម **ខៀវ មុត** អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន សមាជិក

៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឈុំ សុជាត** នាយកទីចាត់ការការងារព្រំដែន ក្រសួងការពារជាតិ សមាជិក

SSC.III.decision

៧-លោក **លឹម សំកុល** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- លោក វរៈសេនីយ៍ឯក **ថ្នាក់ ភានណារ៉ា** អនុប្រធាននាយកដ្ឋាននគរបាលព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

**ប្រការ២:** គណៈប្រតិភូអន្តរក្រសួងដើម្បីពិភាក្សាការងារជាមួយភាគីថៃ ដែលមានបេសកកម្ម និងភារកិច្ច ដូចតទៅ :

១- ចូលរួមចរចា និងពិភាក្សាជាមួយភាគីថៃ លើបញ្ហាជុំវិញការបើកច្រកទ្វារព្រំដែន អូរស្មាច់ ( កម្ពុជា ) - ចុងជាំ ( ថៃ ) ដែលរួមមាន ការបង្កើតកាស៊ីណូ ការកំណត់ខ្សែព្រំដែន ការការពារបរិស្ថាន ការគ្រប់គ្រងរដ្ឋបាលនៅច្រកទ្វារព្រំដែន ការអនុវត្ត និងលើបញ្ហាធ្វើវិសោធនកម្ម លើកិច្ចព្រមព្រៀងឆ្លងដែននៃប្រទេសទាំងពីរ កម្ពុជា - ថៃ ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៧ ហើយនៅពេលនោះ កិច្ចព្រមព្រៀងពុំទាន់បានកំណត់ នូវច្រកទ្វារព្រំដែនអោយបានទូលំទូលាយ នូវអាទិភាពនៃការឆ្លងកាត់ព្រំដែនរបស់ប្រជាជននៅតំបន់ព្រំដែន នៃប្រទេសទាំងពីរ និង ការកំណត់ស្រុកទាំងឡាយ របស់ភាគីទាំងពីរដែលនៅជាប់ព្រំដែនជាដើម ។

២- ត្រៀម និងរៀបចំរាល់ឯកសារពាក់ព័ន្ធ សំរាប់ធ្វើការចរចាជាមួយភាគីថៃ ។

**ប្រការ៣:** សមាជិកគណៈប្រតិភូ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ៤:** គណៈប្រតិភូអន្តរក្រសួងនេះ មានលេខាធិការដ្ឋាននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ហើយអាចប្រើប្រាស់ត្រារបស់ក្រសួងនេះ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

**ប្រការ៥:** គណៈប្រតិភូអន្តរក្រសួងនេះ នឹងអស់សុពលភាព នៅពេលបញ្ចប់បេសកកម្មរបស់ខ្លួន ដូចមានចែងក្នុងប្រការ២ ។

**ប្រការ៦:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៦
-ឯកសារ-កាលប្បវត្តិ